**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង រវាង**
**ក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក**
**និង**
**ប្រតិភូបុគ្គលិក តំណាងកម្មករ សហជីព និងប្រធានក្រុមគ្រប់ផ្នែក**
**ប្រចាំក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក**
**ស្តីពី**
**ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ**
**ដោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារកូវីដ-១៩**

ថ្ងៃទីមួយ ខែវិច្ឆិកា ឆ្នាំពីរពាន់ម្ភៃមួយ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក ដែលមានអាសយដ្ឋានស្ថិតនៅ ផ្លូវលេខ២១អា ភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល បានរៀបចំការប្រជុំមួយរវាងក្រុមហ៊ុន នីអូ មេរីឌាន អ៊ិនដាសស្ទ្រី ហ្គាមេន (ខេមបូឌា) ឯ.ក និងប្រតិភូបុគ្គលិក ព្រមទាំងតំណាងសហជីពប្រចាំក្រុមហ៊ុន ។

ក្នុងអង្គប្រជុំ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់ អំពីស្ថានភាពបច្ចុប្បន្ន ប្រឈមមុខយ៉ាងខ្លាំងនូវ បញ្ហាកង្វះវត្ថុធាតុដើម និងមិនមានអ្នកបញ្ជាទិញ ព្រមទាំងរងផលប៉ះពាល់ជំងឺ COVID-19 ផ្សេងៗ ដែលជាមូលហេតុធ្វើអោយផលិតកម្មមិនអាចដំណើរការបាន ។ ដូច្នេះក្រុមហ៊ុនបានសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន៧១៤នាក់ ក្នុងចំណោមកម្មករ ៧១៤នាក់ រយៈពេល ០២ខែ ដោយចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ និងចូលធ្វើការវិញនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២។ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតឯកភាពទទួលយកប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១.ភាគីក្រុមហ៊ុន ឯកភាពផ្តល់ប្រាក់ឧបត្ថម្ភចំនួន $30 (សាមសិបដុល្លារអាមេរិក) ក្នុងមួយខែ

កិច្ចប្រជុំនេះ បានចប់នៅវេលាម៉ោងដប់ និងសាមសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមកិច្ចព្រមព្រៀងគ្នាដោយស្មារតីយោគយល់គ្នា សហការគ្នា និងការទទួលខុសត្រូវខ្ពស់បំផុត ។

ថ្ងៃចន្ទ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ព.ស ២៥៦៥
ធ្វើនៅកណ្តាល ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១
**ហត្ថលេខា និងត្រានាយកក្រុមហ៊ុន**

# ស្នាមមេដៃ ប្រតិភូបុគ្គលិក តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក

| | | | | | |
|---|---|---|---|---|---|
| អុន សុផុន | ពេញ ពេជ្រ | ហុង វុទ្ធី | ផាត់ វុត្ថា | ស៊ឹម ផានិត | |
| ហៃ ប៊ុនហាន | វ៉ុន ចំរើន | ណាត ដានី | ងួន សុឃីម | សុខ សីវត្តី | |
| ពេញ ពណ្ណរាយ | ហ៊ី សុហ៊ាង | ឯម ស៊ីម៉ៅ | ធី ចន្ធូ | មាលី លាប | |
| គង់ សាវ៉េត | ហឿន ចាន្ទី | លី សារឿន | ទេព សុផារដ្ឋ | កែ វណ្ណា | |
| សាន ផាត | រិន រុន | នី វីណា | វុទ្ធី រដ្ឋ | ពេជ្យ ចាន់ធី | ឈា សុភា |